# ការរំលាយកិច្ចសន្យា

## ១.ការពន្យល់អំពីច្បាប់សារធាតុនៃការរំលាយកិច្ចសន្យា

### ១.១ មូលហេតុនៃការសង្គ្រោះកិច្ចសន្យា

កិច្ចសន្យាត្រូវបានសង្គ្រោះ នៅពេលភាគីនៃកិច្ចសន្យារងនូវការបំពានពីភាគីម្ខាងទៀតនៃកិច្ចសន្យា តាមរយៈការមិនអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យា។ ការមិនអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យា ជាស្ថានភាពដែលកូនបំណុលធ្វើឲ្យគោលដៅនៃកិច្ចសន្យា មិនអាចសម្រេចតាមការព្រមព្រៀង និងធ្វើឲ្យម្ចាស់បំណុលរងការខូចខាត ឬបាត់ទំនុកចិត្តក្នុងការបន្តអនុវត្តកិច្ចសន្យា។ ទម្រង់នៃការមិនអនុវត្តកាតព្វកិច្ច ជាស្ថានភាពដូចខាងក្រោម(CC#389) ៖

**ក.ការអនុវត្តកាតព្វកិច្ចមិនពេញលេញ** ៖ កូនបំណុលបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន ប៉ុន្តែមិនបានត្រឹមត្រូវ ឬមិនទាន់សមស្រប(CC#393)។

ឧទាហរណ៍ ៖ A បានមកខ្ចីលុយ B ហើយ B យល់ព្រម និងបានប្រគល់ប្រាក់កម្ចីឲ្យទៅ A ដោយចំនួនប្រាក់កម្ចីគឺ ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក និងសន្យាសងវិញនៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥។ ដល់កំណត់សង A បានសង ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក រហូតដល់ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៥ ទើប A បានសងបង្គ្រប់ឲ្យទៅ B។ ករណីនេះ ហៅថា ការអនុវត្តកាតព្វកិច្ចមិនពេញលេញ។

**ខ.ការអនុវត្តកាតព្វកិច្ចយឺតយ៉ាវ** ៖ ប្រសិនបើ មានពេលវេលាពិតប្រាកដក្នុងការអនុវត្តកាតព្វកិច្ច កូនបំណុលត្រូវទទួលខុសត្រូវចំពោះការយឺតយ៉ាវនោះ ប្រសិនបើពេលវេលាមិនពិតប្រាកដ កូនបំណុលត្រូវទទួលខុសត្រូវនៅពេល ដឹងអំពីការមកដល់ និងប្រសិនបើមិនកំណត់អំពីពេលវេលាអនុវត្តកាតព្វកិច្ច កូនបំណុលនោះត្រូវទទួលខុសត្រូវ ចំពោះការយឺតយ៉ាវ ក្រោយពេលដែលកូនបំណុលនោះបានទទួលការទាមទារឱ្យអនុវត្ត(CC#391)។

ឧទាហរណ៍ ៖ A បានមកខ្ចីលុយ B ហើយ B យល់ព្រម និងបានប្រគល់ប្រាក់កម្ចីឲ្យទៅ A ដោយបានសន្យាថានឹងប្រគល់ប្រាក់កម្ចីនោះមកឲ្យ B វិញនៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥ ប៉ុន្តែដល់កំណត់សង A មិនបានប្រគល់ប្រាក់កម្ចីនោះទេ រហូតដល់ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៥ ទើប A បានសង B។ ករណីនេះ ហៅថា ការអនុវត្តកាតព្វកិច្ចយឺតយ៉ាវ។

**គ.អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច** ៖ ជាស្ថានភាពដែលមិនអាចអនុវត្តកាតព្វកិច្ចបានដោយសារលក្ខណៈសារធាតុនៃកាតព្វកិច្ចនោះ។

ឧទាហរណ៍ ៖ A (អ្នកលក់) និង B (អ្នកទិញ) បានចុះកិច្ចសន្យាទិញដីមួយកន្លែង ក្នុងតម្លៃ ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក B បានកក់ ៥០.០០០ (ប្រាំម៉ឺន) ដោយសន្យាថា នៅពេលផ្ទេរកម្មសិទ្ធិជាស្ថាពររួចហើយ B យល់ព្រមបង់ប្រាក់បង្គ្រប់ឲ្យ A។ មុនកាលបរិច្ឆេទនៃការប្រគល់ដី ដីបានលេចចូលទឹកទន្លេ ហេតុនេះ Aគ្មានដីប្រគល់ឲ្យ B នោះទេ។ ករណីនេះ ហៅថា អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច (CC#392)។

**ឃ.ករណីផ្សេងៗទៀតដែលគ្មានការអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ច** ៖ ជាស្ថានភាពដែលច្បាប់តម្រូវឱ្យមានកាតព្វកិច្ចក្នុងការអនុវត្ត ឬជាស្ថានភាពដែលត្រូវទទួលខុសត្រូវ(CC#394)។

ឧទាហរណ៍ ៖ កម្មកររោងចក្រទទួលរងរបួស នៅក្នុងអំឡុងពេលកំពុងបំពេញការងារដោយមូលហេតុមិនមានឧបករណ៍សុវត្ថិភាពគ្រប់គ្រាន់ កម្មករអាចទាមទារឱ្យរោងចក្រទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច។

ឧទាហរណ៍ ៖ អ្នកលក់ បានលក់សត្វដែលមានជម្ងឺទៅឱ្យអ្នកទិញ ធ្វើឱ្យសត្វដែលមានជម្ងឺនោះឆ្លងជម្ងឺទៅសត្វផ្សេងៗទៀតរបស់អ្នកទិញ ជាអាទិ៍។

**១.២.វិធីនៃការសង្គ្រោះកិច្ចសន្យា**

នៅពេលកូនបំណុលនិងម្ចាស់បំណុលបង្កើតកិច្ចសន្យា ហើយកូនបំណុលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃកិច្ចសន្យា ដូចជាធ្វើសកម្មភាពណាមួយក្នុងចំណោមសកម្មភាពខាងលើនេះ ច្បាប់បង្កើតវិធានជួយម្ចាស់បំណុលតាមរយៈមធ្យោបាយពហុសង្គ្រោះណាមួយក្នុងចំណោមមធ្យោបាយនានាដែលកំណត់ដោយច្បាប់ ដូចជា ការអនុវត្តកាតព្វកិច្ចដោយបង្ខំ សំណងនៃការខូចខាត និងការរំលាយកិច្ចសន្យា (CC#390)។ ម្ចាស់បំណុលអាចប្រើមធ្យោបាយនេះ លើសពីមួយបាន កុំឲ្យតែធម្មជាតិនៃមធ្យបាយនោះមានលក្ខណៈផ្ទុយគ្នា។

**ក.ការអនុវត្តដោយបង្ខំ** ៖ ជាវិធានចាប់បង្ខំឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយបង្ខំតាមវិធានតុលាការ ប៉ុន្តែប្រសិនបើលក្ខណៈសារធាតុនៃកាតព្វកិច្ចមិនអាចអនុវត្តកាតព្វកិច្ចដោយបង្ខំ ម្ចាស់បំណុលមិនគប្បីប្រើវិធាននេះឡើយ(CC#396)។

ឧទាហរណ៍ ៖ A (ក្រុមហ៊ុនភាពយន្ត) និង B (តារាសំដែង) បានចុះកិច្ចសន្យាថត

ភាពយន្តខ្នាតធំមួយចប់ដោយតារាងសំដែងទទួលបានកម្រៃ ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក ដោយសន្យាថានឹងថតឲ្យចប់ដោយមិនឈប់មុននោះទេ។ថតបាន ០២(ពីរ) ខែ ក៏លែងថត។ ករណីនេះ ក្រុមហ៊ុនភាពយន្ត មិនអាចប្រើវិធានអនុវត្តដោយបង្ខំនោះទេ។

វិធានអនុវត្តដោយបង្ខំ អាចធ្វើបានតាមវិធានបីប្រភេទ គឺវិធានបង្ខំដោយផ្ទាល់ វិធានបង្ខំដោយប្រយោល និងវិធានបង្ខំដោយជំនួស។ វិធានបង្ខំដោយផ្ទាល់ ជាវិធានធ្វើឱ្យសម្រេចនូវកម្មវត្ថុនៃកាតព្វកិច្ចដោយផ្ទាល់ពីសំណាក់ស្ថាប័នអនុវត្ត ដោយសារលក្ខណៈសារធាតុនៃកាតព្វកិច្ចនោះ។ វិធានបង្ខំដោយជំនួស ជាវិធានដែលម្ចាស់បំណុលអាចសម្រេចនូវសិទ្ធិរបស់ខ្លួនដោយខ្លួនឯង ឬតតិយជនធ្វើជំនួសកូនបំណុល និងប្រមូលសោហ៊ុយពីកូនបំណុល ហើយវិធាននេះអាចត្រូវបានអនុវត្ត ប្រសិនបើវិធានាបង្ខំដោយផ្ទាល់គ្មានលក្ខណៈសមស្រប។ វិធានបង្ខំដោយប្រយោល ជាវិធានឱ្យបង់សំណង ប្រសិនបើវិធានបង្ខំដោយផ្ទាល់មិនអាចធ្វើបាន។

ឧទាហរណ៍ ៖ A (ភតិបតី) និង B (ភតិក) បានចុះកិច្ចសន្យាជួលដីមួយកន្លែង ក្នុងតម្លៃ ១.០០០ (មួយពាន់) ដុល្លារអាមេរិក/ខែ។ កិច្ចសន្យាជួលនេះមានរយៈពេល ០៥ (ប្រាំ) ឆ្នាំ។ កិច្ចសន្យាបានកំណត់ថា B អាចសងសំណង់លើដីនោះដើម្បីធ្វើអាជីវកម្ម។ ដល់កាលកំណត់ មិនមាននការបន្តជាថ្មីនូវកិច្ចសន្យាជួល ហេតុនេះ A បានប្រាប់ B ឲ្យរុះរើសំណង់ចេញពីដី ប៉ុន្តែ B មិនព្រម ហេតុនេះ A អាចដាក់ពាក្យប្តឹងទៅតុលាការបង្គាប់ឲ្យ B រុះរើសំណង់នោះ និងនៅពេលសាលក្រមស្ថាពរ គឺ A អាចអនុវត្តបង្ខំដោយផ្ទាល់ចំពោះ B បាន ប៉ុន្តែបើ B នៅតែមិនព្រមធ្វើ គឺ A អាចស្នើសុំអនុវត្តបង្ខំ តាមវិធានជំនួស គឺឲ្យតតិយជនជាអ្នករុះរើ ហើយថ្លៃរុះរើជាបន្ទុករបស់ B ហេតុនេះបើ A បានចេញមុន នាំឲ្យ A មានសិទ្ធិលើបំណុលចំពោះ B ។

**ខ.ការទាមទារសំណងនៃការខូចខាត** ៖ ជាការខូចខាតដែលកើតឡើង មកពីការមិនអនុវត្តកាតព្វកិច្ចតាមខ្លឹមសារនៃកិច្ចសន្យារបស់កូនបំណុល ដែលការមិនអនុវត្តកាតព្វកិច្ចនោះបណ្តាលឲ្យមានការខូចខាតចំពោះម្ចាស់បំណុល (CC#398)។

➤ **សំណងនៃការខូចខាតធម្មតា**

ការខូចខាតធម្មតា សំដៅលើការខូចខាតដែលបានកើតឡើងជាធម្មតា ដោយសារការមិនអនុវត្តកាតព្វកិច្ច (**មាត្រា៤០១ ចំណុចក នៃក្រមរដ្ឋប្បវេណី**)។ ឧទាហរណ៍ Aចុះកិច្ចសន្យាជួលផ្ទះឲ្យB ប៉ុន្តែ ដល់កំណត់ត្រូវប្រគល់ផ្ទះ Aមិនប្រគល់ Bបានទៅជួលសណ្ឋាគារដើម្បីស្នាក់នៅក្នុង១ថ្ងៃ៥០ដុល្លារ សោហ៊ុយចំណាយក្នុង១ថ្ងៃ៥០ដុល្លារ គឺជាការខូចខាតធម្មតាដែលបណ្តាលមកពីការមិនអនុវត្តកាតព្វកិច្ចរបស់A។

➤ **សំណងនៃការខូចខាតពិសេស**

សំណងនៃការខូចខាតពិសេស គឺជាសំណងនៃការខូចខាតដែលកើតឡើងដោយសារកាលៈទេសៈពិសេស ដែលគូភាគីមិនអាចព្យាករណ៍បាន ហេតុនេះ សំណងនៃការខូចខាតពិសេសមិនត្រូវបានទទួលស្គាល់ឡើយក្នុងករណីដែលភាគីមិនអាចព្យាករណ៍បាន **(CC#401)**។ Aបានយកឡានទៅផ្ញើនៅចំណតរបស់B ប្រសិនបើ ឡាននោះបាត់ដោយសារកំហុសរបស់B Aមានសិទ្ធិទាមទារការខូចខាតពីB ការខូចខាតនេះហៅថា ការខូចខាតធម្មតា ប៉ុន្តែចែដន្យក្នុងឡាននោះ Aមានទុកកងដៃពេជ្រ១ ការបាត់បង់កងដៃពេជ្រ គឺជាសំណងនៃការខូចខាតពិសេស ហេតុនេះ ប្រសិនបើA និងB មិនអាចព្យាករណ៍ទុកជាមុនទេ Aមិនអាចទាមទារឲ្យB សងសំណងនៃការខូចខាតពិសេសនេះបានទេ។ ផ្ទុយទៅវិញ ប្រសិនបើ Aប្រាប់ទៅBថា ក្នុងឡានរបស់ខ្ញុំមានកងដៃពេជ្រមានតម្លៃ សូមជួយមើលផង ហើយBយល់ព្រម ករណីនេះA អាចទាមទារសំណងនៃការខូចខាតពិសេស។

➤ **លក្ខខណ្ឌនៃសំណង**

ក្នុងករណី មានការកំណត់ជាមុននូវសំណងនៃការខូចខាត តើលក្ខខណ្ឌដើម្បីឲ្យ កូនបំណុល ទទួលខុសត្រូវចំពោះសំណងនៃការខូចខាត ខុសគ្នាជាមួយនឹងលក្ខខណ្ឌក្នុងការទាមទារសំណង ក្នុងករណីពុំបានកំណត់ទុកជាមុនដែរឬទេ ?

លក្ខខណ្ឌដើម្បីទាមទារសំណងនៃការខូចខាត (CC#398) ដូចជា **(១)** ការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុល **(២)** កំហុសរបស់កូនបំណុល **(៣)** អត្ថិភាពនៃការខូចខាត និង **(៤)** ទំនាក់ទំនងហេតុផល។

ក្នុងករណីនេះ កូនបំណុលត្រូវទទួលខុសត្រូវសងសំណងនៃការខូចខាត ប៉ុន្តែក្នុងករណីមានការកំណត់ជាមុននូវសំណងនៃការខូចខាត លក្ខខណ្ឌក្នុងការទាមទារសំណងមានការប្រែប្រួលខ្លះៗ ដោយយើងមិនអាចឆ្លើយថា ដូចគ្នា ឬខុសគ្នាទាំងស្រុងនោះទេ។ ទោះបីជាមានការកំណត់ទុកជាមុននូវសំណងនៃការខូចខាតក៏ដោយ អត្ថិភាពនៃការមិនអនុវត្តកាតព្វកិច្ចត្រូវតែមាន និងបញ្ហាកំហុស ក៏ត្រូវអនុវត្តដូចគ្នាផងដែរ ហេតុនេះក្នុងករណីកូនបំណុលមានសំអាងថាខ្លួនគ្មានកំហុសក្នុងការមិនអនុវត្តកាតព្វកិច្ច កូនបំណុលអាចបដិសេធការទទួលខុសត្រូវបាន។ ផ្ទុយទៅវិញ ក្នុងករណី មានខចែងដែលខ្លឹមសារថា ទោះបីជាកូនបំណុលមាន ឬគ្មានកំហុស ក៏ដោយកូនបំណុលត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាតដែលបណ្តាលមកពីការមិនអនុវត្តកាតព្វកិច្ច ក្នុងករណីនេះ កូនបំណុលត្រូវតែទទួលខុសត្រូវ ទោះបីជាខ្លួន គ្មានកំហុសក៏ដោយ**(CC#403-1)**។ ម្យ៉ាងវិញទៀត ក្នុងករណី មានការសន្យាពិសេសថា ទោះបីជាកូនបំណុលមានកំហុសចំពោះការមិនអនុវត្តកាតព្វកិច្ចក៏ដោយ កូនបំណុលត្រូវរួចផុតពីការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត? ការសន្យាពិសេសនេះ អាចអនុវត្តបានចំពោះតែករណី

ដែលកូនបំណុលមានកំហុសស្រាលប៉ុណ្ណោះ។ ផ្ទុយទៅវិញ ករណីដែលកូនបំណុលមានកំហុសធ្ងន់ធ្ងរ ឬមានចេតនាទុច្ចរិត ទោះបីជាមានការសន្យាពិសេសបែបនេះក៏ដោយ កូនបំណុលមិនរួចផុតពីការទទួលខុសត្រូវនោះទេ (CC#304-2)។

**គ.ការរំលាយកិច្ចសន្យា** ៖ ជាគោលការណ៍ ភាគីនៃកិច្ចសន្យាអាចរំលាយកិច្ចសន្យាបាន បើបានបំពេញតាមលក្ខខណ្ឌច្បាប់ ឬភាគីព្រមព្រៀងគ្នា ជាអាទិ៍។ ការរំលាយកិច្ចសន្យា បានធ្វើឡើងតាមរូបភាព ០៣ (បី) យ៉ាង ទី១ ការរំលាយកិច្ចសន្យាតាមច្បាប់ ទី២ ការរំលាយដែលបានកំណត់ក្នុងកិច្ចសន្យា និងទី៣ការរំលាយកិច្ចសន្យាតាមការព្រមព្រៀង។

**ការរំលាយកិច្ចសន្យាតាមច្បាប់** តម្រូវឲ្យបំពេញលក្ខខណ្ឌ ២ (ពីរ) គឺលុះត្រាតែជាកិច្ចសន្យាអញ្ញមញ្ញ និងភាគីម្ខាងទៀតបានបំពានកិច្ចសន្យានោះធ្ងន់ធ្ងរ (CC#407)។

ការបំពានកិច្ចសន្យាធ្ងន់ធ្ងរគឺជាស្ថានភាព (CC#408) ដូចខាងក្រោម ៖

➤ការដាស់តឿន ៖ ភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀតដែលមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ ដោយបានកំណត់អំឡុងពេលសមរម្យដើម្បីអនុវត្តកាតព្វកិច្ច ហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តនៅក្នុងអំឡុងពេលនោះ។

ឧទាហរណ៍ ៖ A បានមកខ្ចីលុយ B ហើយ B យល់ព្រម និងបានប្រគល់ប្រាក់កម្ចីឲ្យទៅ A ដោយចំនួនប្រាក់កម្ចីគឺ ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក និងសន្យាសងវិញនៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥។ ដល់កំណត់សង A មិនបានសង B បានទាមទារឲ្យសងក្នុងអំឡុងពេលមួយសប្តាហ៍ ប៉ុន្តែមួយសប្តាហ៍បានកន្លងផុតទៅហើយ A នៅតែមិនសង ករណីនេះ ហៅថាមានការបំពានកិច្ចសន្យាធ្ងន់ធ្ងរ។

➤ភាគីមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់នៅក្នុងកិច្ចសន្យា ៖ ករណីគោលបំណងនៃកិច្ចសន្យាមិនបានសម្រេចសោះ បើភាគីមិនបានអនុវត្តតាមពេលកំណត់។

ឧទាហរណ៍ ៖ A ជាអ្នកទិញ B ជាអ្នកលក់ កម្មវត្ថុនៃការលក់-ទិញ គឺនំអាពាហ៍ពិពាហ៍ ក្នុងករណី A បានបញ្ជាទិញនំអាពាហ៍ពិពាហ៍ពី B ដើម្បីយកមកប្រើនៅក្នុងកម្មវិធីអាពាហ៍ពិពាហ៍ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៦។ ដល់កាលបរិច្ឆេទនៃអាពាហ៍ពិពាហ៍ នំអាពាហ៍ពិពាហ៍មិនទាន់ធ្វើរួច លុះ ០២ ថ្ងៃ បន្ទាប់ទើបរួច ករណីនេះ ហៅថាមានការបំពានកិច្ចសន្យាធ្ងន់ធ្ងរ។

➤ភាគីមិនបានអនុវត្តករណីយកិច្ចផ្តល់តាវកាលិកចម្បងរបស់ខ្លួន ៖ ករណីខ្លឹមសារនៃតាវកាលិកដែលកើតពីកិច្ចសន្យាមិនអាចអនុវត្តបានដោយសារស្ថានភាពជាក់ស្តែង

ឧទាហរណ៍ ៖ A ជាអ្នកទិញ B ជាអ្នកលក់ កម្មវត្ថុនៃការលក់-ទិញ គឺផ្ទះ ប៉ុន្តែផ្ទះនោះជាប់សិទ្ធិជួលរបស់ C រយៈពេល ១០ ឆ្នាំ។ កាតព្វកិច្ចចម្បងរបស់អ្នកលក់ គឺផ្ទេរកម្មសិទ្ធិ និងផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ ហេតុការណ៍នេះគឺច្បាស់លាស់ហើយ ថា អ្នកលក់មិនអាចផ្ទេរការកាន់កាប់ឲ្យទៅអ្នកទិញ។

➤ការបំពានកិច្ចសន្យាមានភាពហួសហេតុ ៖ ជាស្ថានភាពដែលធ្វើឱ្យបាត់បង់ទំនុកចិត្តរវាងគូភាគី ហើយមិនអាចជឿជាក់ថានឹងអនុវត្តកាតព្វកិច្ចនាពេលអនាគត

ឧទាហរណ៍ ៖ A ជាម្ចាស់ការ B ជាម៉ៅការ កម្មវត្ថុនៃការម៉ៅការ គឺលាបថ្នាំផ្ទះឲ្យហើយក្នុងអំឡុងពេល ០១ ដោយប្រើពណ៌បៃតងខ្ចី ជាអាទ៍។ B បានលាបពណ៌ថ្នាំផ្ទះ ដោយប្រើពណ៌បៃតងចាស់ ហើយអំឡុងពេល ២០ ថ្ងៃ បានកន្លងផុត។

**ការរំលាយដែលបានកំណត់ក្នុងកិច្ចសន្យា** ៖ ភាគីនៃកិច្ចសន្យាអាចសន្យាជាមួយគ្នាអំពីលក្ខខណ្ឌនៃការរំលាយកិច្ចសន្យា ដូចជា ភាគី "ក" និងភាគី "ខ" បានចុះកិច្ចសន្យាជួលដី ដោយភាគី"ក" ជាភតិបតី ហើយភាគី"ខ" ជាភតិក: នៅក្នុងកិច្ចសន្យាជួលបានកំណត់ថា បើភាគី "ខ" ខកខានបង់ថ្លៃឈ្នួលដី០២(ពីរ) ខែជាប់គ្នា ចាត់ទុកថាភាគី "ខ" ឈប់ជួល ហើយកិច្ចសន្យាជួលត្រូវបានរំលាយ ប្រាក់កក់នឹងក្លាយជាប្រយោជន៍របស់ភាគី"ក"។ ករណីនេះហៅថា ការព្រមព្រៀងជាមុនអំពីលក្ខខណ្ឌនៃការរំលាយកិច្ចសន្យា(CC#414-1)។

**ការរំលាយដោយការព្រមព្រៀង** ៖ ទោះបីជាមិនសន្យាមុន ក៏ភាគីអាចព្រមព្រៀងគ្នារំលាយកិច្ចសន្យាបាន ដូចជា ភាគី "ក" និងភាគី "ខ" បានចុះកិច្ចសន្យាជួលដី ដោយភាគី"ក"ជាភតិបតី ភាគី "ខ" ជាភតិក:។ រយៈពេលជួលគឺ ០៣ (បី) ឆ្នាំ ប៉ុន្តែជួលបាន ០១ (មួយ) ឆ្នាំ ភាគី "ខ" ស្នើសុំឈប់ជួលមុនកាលកំណត់ ហើយភាគី "ក" យល់ព្រម និងបានព្រមព្រៀងគ្នារំលាយកិច្ចសន្យានេះ។ ករណីនេះហៅថាការព្រមព្រៀងរំលាយកិច្ចសន្យា(CC#414-2)។

ភាគីដែលមានសិទ្ធិរំលាយ អាចរំលាយកិច្ចសន្យា ដោយបង្ហាញឆន្ទៈរំលាយទៅភាគីម្ខាងទៀត ដោយមិនអាចដកវិញបានទេ ប៉ុន្តែអាចដាក់លក្ខខណ្ឌបង្អង់បាន។ មួយវិញទៀត ពាក់ព័ន្ធនឹងសិទ្ធិរំលាយ គឺសិទ្ធិរំលាយត្រូវរលត់ ក្នុងករណីដែល ភាគីមានសិទ្ធិរំលាយបានធ្វើឱ្យខូចខាត ឬបាត់បង់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ឬមិនអាចសងវត្ថុនោះបានដោយចេតនា ឬវត្ថុនោះក្លាយជាវត្ថុប្រភេទផ្សេង ដោយការកែច្នៃ ឬផ្លាស់ប្តូរទម្រង់ដោយចេតនា និងប្រសិនបើភាគីបានអនុវត្តសិទ្ធិរំលាយ ភាគីនោះត្រូវសងជាប្រាក់នូវតម្លៃនៃវត្ថុដែលជាកម្មវត្ថុនោះត្រឹម

តម្លៃ ដែលបានកំណត់នៅក្នុងកិច្ចសន្យា លើកលែងតែ ភាគីម្ខាងទៀតមានកំហុស ភាគីនោះមិនចាំបាច់សងទេ(CC#409)។

អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យា ដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច និងសិទ្ធិទាមទារបដិទាន មានអំឡុងពេល ០៥ (ប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃដែលមិនបានអនុវត្តកាតព្វកិច្ច(CC#413)។

### ១.៣.អានុភាពនៃការរំលាយកិច្ចសន្យា

នៅពេលកិច្ចសន្យាត្រូវបានរំលាយ នាំឲ្យបង្កើតនូវអានុភាពគតិយុត្ត ដូចខាងក្រោម (CC#411) ប៉ុន្តែមិនអាចធ្វើឱ្យខូចប្រយោជន៍ត្រឹមត្រូវរបស់តតិយជន បានឡើយ ៖

**ក.ការរួចផុតពីកាតព្វកិច្ច** ៖ ភាគីរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យាលើកលែងតែករណីយកិច្ចសងការខូចខាត។

ឧទាហរណ៍ ៖ A ជាអ្នកទិញ B ជាអ្នកលក់ កម្មវត្ថុនៃការលក់ទិញ គឺរថយន្ត ដោយ B បានសន្យានឹងប្រគល់រថយន្តមកឲ្យ A នៅថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៦ ហេតុនេះនៅពេលចុះកិច្ចសន្យា (០១ ខែ កក្កដា ឆ្នាំ ២០១៦) A និយាយថាបង់ប្រាក់ B គ្រប់ចំនួន នៅពេល B ប្រគល់រថយន្ត។ B គ្មានរថយន្តប្រគល់ឲ្យទេ ពីព្រោះចោរលួចបាត់។

**ខ.កាតព្វកិច្ចបដិទាន** ៖ ភាគីដែលបានទទួលតាវកាលិកនៃកិច្ចសន្យាតែមួយភាគ ឬទាំងអស់ ត្រូវមានករណីយកិច្ចសងតាវកាលិកនោះទៅភាគីម្ខាងទៀត ដើម្បីឱ្យភាគីម្ខាងទៀតទទួលបដិទាន និងប្រសិនបើភាគីទាំងសងខាងមានករណីយកិច្ចធ្វើបដិទានទៅវិញទៅមក ករណីយកិច្ចទាំងនោះ ត្រូវអនុវត្តនៅពេលជាមួយគ្នា។

ឧទាហរណ៍ ៖ A ជាអ្នកទិញ B ជាអ្នកលក់ កម្មវត្ថុនៃការលក់ទិញ គឺរថយន្ត ដោយ B បានប្រគល់រថយន្តមកឲ្យ A នៅពេលចុះកិច្ចសន្យា។ ប៉ុន្តែ A មិនទាន់បង់ប្រាក់ ដោយសន្យាបង់នៅខែក្រោយ ប៉ុន្តែ A នៅតែមិនបង់។ B អាចរំលាយកិច្ចសន្យា និងទាមទារឲ្យ A ប្រគល់រថយន្តមកឲ្យខ្លួនវិញ។ ករណីនេះ ហៅថាកាតព្វកិច្ចបដិទាន។

**គ.ការសងការប្រាក់** ៖ ភាគីដែលមានករណីយកិច្ចសងជាប្រាក់ដោយការរំលាយ ត្រូវសងជាមួយនឹងការប្រាក់ដោយគិតចាប់ ពីថ្ងៃដែលបានទទួលប្រាក់ដើម ភាគីដែលមានករណីយកិច្ចបង្វិលវត្ថុ ឬតាវកាលិកផ្សេងដែលខ្លួនបានទទួលពីភាគី ម្ខាងទៀតដោយការរំលាយ ត្រូវសងទាំងផលដែលបានទទួលពីវត្ថុ ឬតាវកាលិកនោះ។

ឧទាហរណ៍ ៖ A ជាអ្នកទិញ B ជាអ្នកលក់ កម្មវត្ថុនៃការលក់ទិញ គឺរថយន្ត ដោយ B បានសន្យានឹងប្រគល់រថយន្តមកឲ្យ A នៅថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៦ ប៉ុន្តែនៅពេលចុះកិច្ចសន្យា (០១ ខែ កក្កដា ឆ្នាំ ២០១៦) A បានបង់ប្រាក់ B គ្រប់ចំនួន។ ដល់កាលបរិច្ឆេទប្រគល់រថយន្ត B គ្មានរថយន្តប្រគល់ឲ្យទេ ពីព្រោះចោរលួចបាត់ ហេតុនេះ នៅពេលរំលាយកិច្ចសន្យា A អាចទាមទារឲ្យ B ប្រគល់ប្រាក់ដើម និងការប្រាក់ គិតចាប់ពីថ្ងៃបានទទួលប្រាក់ដើម ដោយគិតអត្រាការប្រាក់ ៥%/ឆ្នាំ។

## ២.ការទាមទារតាមផ្លូវតុលាការ

ផ្អែកតាមមាត្រា ៤០៩ នៃក្រមរដ្ឋប្បវេណី វិធីនៃការរំលាយកិច្ចសន្យា គឺជាការបង្ហាញ ឆន្ទៈរបស់ភាគីម្ខាងទៅភាគីម្ខាងទៀត។ ការរំលាយកិច្ចសន្យា មិនត្រូវការអន្តរាគមន៍របស់តុលាការនោះទេ ហើយប្រសិនបើ ភាគីបានស្នើសុំឲ្យតុលាការចេញសាលក្រម រំលាយកិច្ចសន្យា ជាអាទិ៍ ខ្លឹមសារនៃការទាមទារនេះ ត្រូវបានចាត់ទុកថាគ្មានផលប្រយោជន៍នៃបណ្ដឹង (CCP#74) ដែលជាមូលហេតុនៃការចេញសាលក្រមលើកចោលបណ្ដឹងមិនឆ្លងកាត់ការទាញហេតុផល ដោយផ្ទាល់មាត់ (CCP#81)។

ប្រសិនបើភាគីបានបង្ហាញឆន្ទៈតាមផ្លូវតុលាការរួចហើយ ដោយមានមូលហេតុតាមផ្លូវច្បាប់ក្នុងការរំលាយកិច្ចសន្យា ជាអាទិ៍ ប៉ុន្តែភាគីម្ខាងទៀត មិនអនុវត្តកាតព្វកិច្ច ដែលកើតចេញពីអានុភាពនៃការរំលាយកិច្ចសន្យា ជាអាទិ៍ អន្តរាគមន៍របស់តុលាការមានភាពចាំបាច់ ដើម្បីសម្រេចគោលបំណងរបស់ម្ចាស់បំណុលឲ្យមានលក្ខណៈជាសត្យានុម័ត។

ការសរសេរពាក្យបណ្ដឹងឲ្យបានត្រឹមត្រូវ តាមនីតិវិធី គឺមានភាពចាំបាច់ខ្លាំងណាស់សម្រាប់ មេធាវី ជាអាទិ៍ ក្នុងការអនុវត្តសិទ្ធិរបស់ភាគីនៅចំពោះមុខតុលាការ ក្នុងនាមជាអ្នកតំណាងដោយអាណត្តិ។ ផ្អែកតាមមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី តម្រូវឲ្យភាគីបំពេញនូវចំណុចសារធាតុមួយចំនួន ដូចជា ទី១ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ ទី២ អង្គហេតុចាំបាច់សម្រាប់បញ្ជាក់ការទាមទារ និងទី៣ អង្គហេតុដែលជាមូលហេតុនៃការទាមទារ។

នៅពេលពាក្យបណ្ដឹងបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌទម្រង់ហើយ តុលាការនឹងបញ្ជូនពាក្យបណ្ដឹងទៅចុងចម្លើយ ហើយចុងចម្លើយត្រូវធ្វើឯកសារចម្លើយ ដើម្បីឆ្លើយតបជាមួយនឹងពាក្យបណ្ដឹងនោះ(CCP#101)។ ឯកសារចម្លើយគឺជាប្រភេទមួយនៃឯកសារត្រៀម ដែលភាគីចុងចម្លើយត្រូវដាក់មកតុលាការ ដើម្បីឆ្លើយតបនឹងការទាមទាររបស់ដើមចោទ។

ឯកសារចម្លើយ (មធ្យោបាយតទល់) ត្រូវបំពេញនូវចំណុចសារធាតុមួយចំនួន ដូចជា ទី១ ការឆ្លើយតបនឹងខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ ទី២ ការទទួលស្គាល់ ឬមិនទទួលស្គាល់អង្គហេតុដែលអះអាងដោយដើមចោទ ដូចមានកំណត់ក្នុងពាក្យបណ្តឹង ទី៣ ការតវ៉ាចំពោះអង្គហេតុដែលអះអាងដោយដើមចោទ (ប្រសិនបើមាន) ទី៤ បើបានអះអាងអំពីអង្គហេតុតវ៉ា ជាអាទិ៍ ត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់ភស្តុតាង (បើមាន)។

នៅពេលដែលចុងចម្លើយបានធ្វើឯកសារចម្លើយ ដើម្បីឆ្លើយតបនឹងពាក្យបណ្តឹងរបស់ដើមចោទ ហើយបានដាក់មកតុលាការ តុលាការនឹងបញ្ជូនឯកសារចម្លើយនោះទៅដើមចោទ ដើម្បីឲ្យដើមចោទធ្វើការការពារខ្លួន (មធ្យោបាយការពារ) យើងហៅ ការឆ្លើយតបនោះថា ឯកសារត្រៀមលើកទី១របស់ដើមចោទ។

ឯកសារត្រៀមលើកទី១របស់ដើមចោទ ត្រូវបំពេញនូវចំណុចសារធាតុមួយចំនួន ដូចជា ទី១ ការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះអង្គហេតុដែលមានកំណត់ក្នុងឯកសារចម្លើយ ទី២ ការអះអាងអង្គហេតុតវ៉ាតប (បើឯកសារចម្លើយមានអង្គហេតុតវ៉ា)។

ប្រសិនបើបានបំពេញកិច្ចខាងលើនេះហើយ តុលាការនឹងបន្តនីតិវិធី ដោយកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង **(CCP#80)**។

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញមានសារៈសំខាន់ខ្លាំង ប្រសិនបើ កំណត់មិនបានច្បាស់លាស់ ឬខ្លឹមសារនោះមិនអាចអនុវត្តជាសត្យានុម័តនោះទេ ធ្វើឲ្យការធ្វើនីតិវិធីបណ្តឹងគ្មានន័យ ហើយជាគោលការណ៍តុលាការចេញសាលក្រម តាមការស្នើសុំ ឬការទាមទាររបស់ភាគី មានន័យថា នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រម គឺ អនុវត្តតាមអត្ថន័យនៃការទាមទារក្នុងពាក្យបណ្តឹង ប្រសិនបើការទាមទារនោះមានលក្ខណៈត្រឹមត្រូវតាមច្បាប់សារធាតុ ដោយមានភស្តុតាងបញ្ជាក់ ជាអាទិ៍។

សេចក្តីសម្រេចបញ្ចប់នៃសាលក្រម គឺជាលទ្ធផលនៃការវិនិច្ឆ័យ ដោយភ្ជាប់ជាមួយនឹងសំអាងហេតុ។ សំអាងហេតុគឺជាវិចារណាកិច្ចគតិយុត្ត ដោយភ្ជាប់ជាមួយនឹងខ្លឹមសារនៃច្បាប់សារធាតុ និងភស្តុតាង។

សេចក្តីសម្រេចបញ្ចប់នៃសាលក្រម មិនអាចសម្រេចនូវចំណុចដែលភាគីមិនបានទាមទារនោះទេ និងចំណុចដែលភាគីបានទាមទារត្រូវសម្រេច ទទួលស្គាល់ ឬមិនទទួលស្គាល់។ ទោះបីជាសិទ្ធិរបស់ភាគីមានច្រើនជាងអ្វីដែលបានស្នើសុំក៏ដោយ និងតុលាការប្រមើលឃើញថា អាចមានលើសក៏ដោយ ក៏តុលាការមិនអាចសម្រេចបាននោះទេ**(CCP#182)**។

## ករណីសិក្សាទី១

X ជាអ្នកលក់ Y ជាអ្នកទិញ កម្មវត្ថុនៃការលក់ទិញ គឺដីនិងផ្ទះ (L) តម្លៃនៃការលក់ទិញគឺ ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក។ នៅក្នុងកិច្ចសន្យាបានកំណត់អំពីរបៀបនៃការទូទាត់ប្រាក់ ដោយកក់ប្រាក់ចំនួន ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក នៅថ្ងៃចុះកិច្ចសន្យា និងប្រាក់នៅសល់ចំនួន ៧០.០០០ (ប្រាំពីរម៉ឺន) ដុល្លារអាមេរិក ត្រូវប្រគល់នៅពេលកម្មសិទ្ធិនៃដីនិងផ្ទះនេះត្រូវបានផ្ទេរជាស្ថាពរពីឈ្មោះ X មកឈ្មោះ Y។ ការលក់ទិញនេះបានធ្វើឡើងតាមលិខិតយថាភូត និងបានផ្ទេរចុះបញ្ជីពីឈ្មោះ X មកឈ្មោះ Y។ X បានប្រគល់ដីនិងផ្ទះនោះឲ្យទៅ Yរួចហើយ។ បច្ចុប្បន្ន Y កំពុងកាន់កាប់ ដីនិងផ្ទះនោះ។ ប៉ុន្តែ Y មិនបង់ប្រាក់ដែលនៅសល់ឲ្យទៅ X នោះទេ។ **X មានបំណងយកដីនិងផ្ទះនោះមកវិញ។ តើ X ត្រូវធ្វើដូចម្តេច?**

## ករណីសិក្សាទី២

X ជាភតិបតី Y ជាភតិកៈ កម្មវត្ថុនៃការជួក គឺដីនិងផ្ទះ តម្លៃនៃកាជួលគឺ US$២.០០០/ខែ (ពីរពាន់ដុល្លារអាមេរិកក្នុងមួយខែ) រយៈពេលជួល គឺ ២៤ (ម្ភៃបួន) ខែ។ នៅក្នុងកិច្ចសន្យាបានកំណត់អំពីរបៀបនៃការបង់ប្រាក់ឈ្នួល ដោយកក់ប្រាក់ចំនួន៤.០០០(បួនពាន់) ដុល្លារអាមេរិក នៅថ្ងៃចុះកិច្ចសន្យា សម្រាប់ធានាការអនុវត្តតាមខ្លឹមសារនៃកិច្ចសន្យា។ ប្រាក់ឈ្នួលត្រូវបង់ដើមខែ បើខកខានបង់ពីរខែ ចាត់ទុកថាឈប់ជួល ហើយកិច្ចសន្យាត្រូវរំលាយជាស្វ័យប្រវត្តិ។ Y ជួលបាន ០៦ (ប្រាំមួយ) ខែ ក៏ខកខានបង់ប្រាក់ឈ្នួលរយៈពេល ០៣ (បី) ខែ ជាប់គ្នា។ X បានដាស់តឿន Yឲ្យបង់ប្រាក់ ប៉ុន្តែគ្មានដំណោះស្រាយ។ បច្ចុប្បន្ន Y កំពុងបន្តស្នាក់នៅលើ ដីនិងផ្ទះនោះ។ ប៉ុន្តែ Y មិនបង់ប្រាក់ឲ្យទៅ Xនោះទេ។ **Xមានបំណងយកដីនិងផ្ទះនោះមកវិញ។ តើ X ត្រូវធ្វើដូចម្តេច?**

## ករណីសិក្សាទី៣

នៅថ្ងៃទី១ ខែ កញ្ញា ឆ្នាំ២០១៦ X បានឲ្យ A ខ្ចីប្រាក់ចំនួន ១០០,០០០$ ដោយកំណត់ពេលសងនៅថ្ងៃទី៣១ ខែ សីហា ឆ្នាំ២០១៧។ ប៉ុន្តែ ទោះបីជាដល់ថ្ងៃកំណត់សងនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ ក៏ដោយ ក៏ A មិនសងប្រាក់នោះទៅ X នោះទេ។ ហេតុនេះ នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៧ X បានទៅការិយាល័យមេធាវីរបស់ Y ដើម្បីពិគ្រោះយោបល់រឿងក្តីនេះ និងបានពឹងពាក់ Y ក្នុងរឿងក្តីនេះ។ នៅពេលនោះ X បានបង់ប្រាក់មុនចំនួន ១០០០$ និងបានធ្វើកិច្ចសន្យាដែលមានខ្លឹមសារថា ពេលក្រោយ បើសិនជា A សងប្រាក់ក្នុងរឿងក្តីនេះទៅឲ្យ X នោះ X នឹងបង់ថ្លៃសេវាឈ្នះក្តីចំនួន១០% នៃប្រាក់ដែល A បានសងនៅទៅឲ្យ Y។ ប៉ុន្តែក្រោយមក X បានឮរឿងពីមិត្តភក្តិ B មកថា មេធាវី Y ពូកែនិយាយណាស់ ប៉ុន្តែមិនព្រមធ្វើការនោះទេ ហេតុនេះហើយ X ចង់បញ្ចប់កិច្ចសន្យាជាមួយមេធាវី Y ខាងលើ។

<u>តើ X ត្រូវធ្វើដូចម្តេច ដើម្បីបានប្រាក់ទាំងនោះមកវិញ?</u>